ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងរវាងនាយិកាក្រុមហ៊ុនសុខៈរីវើឡោញនិងតំណាងកម្មករនិយោជិក
# ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២៨ ខែ មីនា ឆ្នាំ ២០២២ វេលាម៉ោង ៩ និង ៣០នាទី នៅក្នុងក្រុមហ៊ុនភោជនីយដ្ឋានសុខៈរីវើឡោញមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនថា ដោយសារការរីករាលដាលនិងចម្លងនៃជំងឺរលាកសួតប្រភេទថ្មីCovid-19ដែលជាហេតុបណ្តាលអោយមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកហើយក៏ជាហេតុដែលធ្វើអោយក្រុមហ៊ុនទទួលរងការខាតបង់ មិនមានប្រាក់ចំណូលសំរាប់ទ្រទ្រង់ប្រតិបត្តិការណ៍បន្តទៀតបាន។

ហេតុដូចនេះក្រុមហ៊ុនបានសំរេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកទាំងអស់ ចំនួន២៣នាក់ (ស្រី០៥នាក់)រយៈពេល៦០ថ្ងៃដោយគិតចាប់ពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២២ រហូតដល់ទី០៧ ខែមិថុនា ឆ្នាំ២០២២នៅក្នុងកំឡុងពេលនៃការព្យួរនេះកម្មករនិយោជិកនឹងមិនទទួលបានអត្ថប្រយោជន៍អ្វីពីក្រុមហ៊ុនឡើយ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីនាថ្ងៃខែឆ្នាំដដែល ដោយសារភាគីទាំងសងខាងមានការស្និទ្ធស្នាលនិងយោគយល់គ្នាក្រោមស្មារតីទទួលនិងសហការគ្នាយ៉ាងរលូន។

ថ្ងៃចន្ទ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័កព.ស២៥៦៥
សៀមរាប ថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២

ហត្ថលេខា និងត្រា នាយិកា

ជុនតាប់

តំណាងកម្មករនិយោជិក